ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ១៦៣ គ.ជ.ប. ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការប្រកាសផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ថ្ងៃអាទិត្យ ទី២៥ ខែកុម្ភៈ ឆ្នាំ២០២៤

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៦ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១១ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០១០ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២២៣/២៥៨៩ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ០២៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យប្រើបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ៥២១ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ស្តីពីការដាក់ឱ្យប្រើបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- យោងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤)
- យោងតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលភូមិភាគ (ទ.១១១៧គ៣) និងរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប

- យោងប្រតិទិនសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤
- យោងស្មារតីអង្គប្រជុំ គ.ជ.ប ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤

## សម្រេច

**ប្រការ ១.-**

ប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ថ្ងៃអាទិត្យ ទី២៥ ខែកុម្ភៈ ឆ្នាំ២០២៤ ដែលមានលទ្ធផលដូចក្នុងតារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមមណ្ឌលភូមិភាគភ្ជាប់មកជាមួយ។

**ប្រការ ២.-**

លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតដូចមានចែងក្នុងប្រការ១ មានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ប្រការ ៣.-**

គ្រប់គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ អាចប្តឹងតវ៉ាអំពីលទ្ធផលមួយផ្នែក ឬលទ្ធផលទាំងអស់នៃការបោះឆ្នោតដូចមានចែងក្នុងប្រការ១ និងប្រការ២ ខាងលើ ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្ននៅម៉ោង ១០:០០ព្រឹក ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤។

**ប្រការ ៤.-**

អគ្គលេខាធិការ គ.ជ.ប ត្រូវផ្សព្វផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ជាសាធារណៈឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ២០២៤

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**

**ចម្លងទូលថ្វាយៈ**

- ព្រះមហាក្សត្រ

**ចម្លងជូនៈ**

- ក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រឹទ្ធសភា
- រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត
- បណ្ណសារដ្ឋានជាតិ

" ដើម្បីជូនជ្រាប "

- ដូចប្រការ ៤

" ដើម្បីអនុវត្ត "

- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

## តារាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥

### ថ្ងៃអាទិត្យ ទី២៥ ខែកុម្ភៈ ឆ្នាំ២០២៤

| ល.រ | មណ្ឌលបោះឆ្នោត | រាជធានី ខេត្ត | | សំឡេងឆ្នោតដែលគណបក្សនយោបាយទទួលបាន | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | ចំនួន | ឈ្មោះ | ប្រជាជនកម្ពុជា | ឆន្ទៈខ្មែរ | ហ៊្វុនស៊ិនប៉ិច | កម្លាំងជាតិ | |
| 1 | ភូមិភាគទី១ | 1 | ភ្នំពេញ | 817 | 88 | 1 | | |
| | **សរុប** | | | **817** | **88** | **1** | | |
| 2 | ភូមិភាគទី២ | 2 | កំពង់ចាម | 667 | 151 | 1 | 4 | |
| | | | ត្បូងឃ្មុំ | 454 | 88 | | | |
| | **សរុប** | | | **1,121** | **239** | **1** | **4** | |
| 3 | ភូមិភាគទី៣ | 1 | កណ្ដាល | 779 | 130 | 4 | 12 | |
| | **សរុប** | | | **779** | **130** | **4** | **12** | |
| 4 | ភូមិភាគទី៤ | 5 | បន្ទាយមានជ័យ | 466 | 69 | | 4 | |
| | | | បាត់ដំបង | 706 | 118 | | 6 | |
| | | | សៀមរាប | 544 | 22 | 1 | 107 | |
| | | | ប៉ៃលិន | 47 | 4 | | 1 | |
| | | | ឧត្ដរមានជ័យ | 148 | 5 | | | |
| | **សរុប** | | | **1,911** | **218** | **1** | **118** | |
| 5 | ភូមិភាគទី៥ | 3 | កំពត | 499 | 65 | | 1 | |
| | | | តាកែវ | 657 | 82 | | 1 | |
| | | | កែប | 31 | 1 | | | |
| | **សរុប** | | | **1,187** | **148** | | **2** | |
| 6 | ភូមិភាគទី៦ | 2 | ព្រៃវែង | 724 | 166 | 1 | 2 | |
| | | | ស្វាយរៀង | 437 | 79 | | 2 | |
| | **សរុប** | | | **1,161** | **245** | **1** | **4** | |
| 7 | ភូមិភាគទី៧ | 5 | កំពង់ឆ្នាំង | 364 | 50 | | 15 | |
| | | | កំពង់ស្ពឺ | 555 | 65 | | | |
| | | | កោះកុង | 148 | 20 | | | |
| | | | ពោធិ៍សាត់ | 336 | 8 | | | |
| | | | ព្រះសីហនុ | 172 | 8 | | | |
| | **សរុប** | | | **1,575** | **151** | | **15** | |
| 8 | ភូមិភាគទី៨ | 6 | កំពង់ធំ | 459 | 56 | 10 | 64 | |
| | | | ក្រចេះ | 259 | 43 | | | |
| | | | មណ្ឌលគិរី | 108 | | | | |
| | | | ព្រះវិហារ | 273 | 42 | | 14 | |
| | | | រតនគិរី | 242 | 19 | | | |
| | | | ស្ទឹងត្រែង | 160 | 15 | 1 | 1 | |
| | **សរុប** | | | **1,501** | **175** | **11** | **79** | |
| | **សរុបរួម** | **25** | | **10,052** | **1,394** | **19** | **234** | |

ថ្ងៃព្រហស្បតិ៍ ៥កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែកុម្ភៈ ឆ្នាំ២០២៤